ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងទេសចរណ៍**

**លេខ** ១៤៤ ណណស

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០១០

## ជម្រាបជូន

## លោកប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា

**កម្មវត្ថុ** : សំណើសុំអញ្ជើញថ្នាក់ដឹកនាំ និងមន្ត្រីជំនាញចូលរួមប្រជុំពិគ្រោះយោបល់លើគម្រោងរៀបចំអភិវឌ្ឍន៍តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង។

**យោង** : អនុក្រិត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១០ ស្តីពីការកំណត់តំបន់ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូន **លោកប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា** មេត្តាជ្រាបថា: ក្រសួងទេសចរណ៍ នឹងរៀបចំកិច្ចប្រជុំពិគ្រោះយោបល់លើគម្រោងអភិវឌ្ឍន៍ និងធ្វើការស្រាវជ្រាវប្រវត្តិតំបន់ ទេសចរណ៍ប្រវត្តិសាស្ត្រអន្លង់វែង ខេត្តឧត្តរមានជ័យ ដែលនឹងប្រព្រឹត្តទៅនៅ**ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១០ វេលាម៉ោង ៨ :៣០ នាទីព្រឹក នៅទីស្តីការក្រសួងទេសចរណ៍ បន្ទប់លេខ៤២២** ដោយមានការចូលរួម ពីក្រសួងស្ថាប័នពាក់ព័ន្ធ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកប្រធាន** មេត្តាពិនិត្យ និងអនុញ្ញាតឱ្យថ្នាក់ដឹកនាំ និងមន្ត្រីជំនាញរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាអញ្ជើញចូលរួមក្នុងកិច្ចប្រជុំខាងលើដោយអនុគ្រោះ។

សូម **លោកប្រធាន** មេត្តាទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ។

**រដ្ឋមន្ត្រី**

ព្រះរាជាណាចក្រកម្ពុជា ក្រសួងទេសចរណ៍

**ថោង ខុន**